អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី
LOLC (Cambodia) Plc.

# របាយការណ៍ប្រចាំត្រីមាសទី១

## គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១

www.lolc.com.kh

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | ត្រីមាសទី១ ឆ្នាំ២០២១ | ឆ្នាំ២០២០ |
|---|---|---|
| ទ្រព្យសកម្មសរុប (លានរៀល) | ៤.៣៤៥.៩៨៤ | ៤.៣៣៤.៣៣៥ |
| បំណុលសរុប (លានរៀល) | ៣.៥៦៥.៩០០ | ៣.៦០១.៤៧៧ |
| មូលធនសរុប (លានរៀល) | ៧៨០.០៨៤ | ៧៣២.៨៥៨ |
| **លទ្ធផលហិរញ្ញវត្ថុ** | **ត្រីមាសទី១ ឆ្នាំ២០២១** | **ត្រីមាសទី១ ឆ្នាំ២០២០** |
| ចំណូលការប្រាក់ (លានរៀល) | ១៧១.៦៥៥ | ១៦៨.៦១៤ |
| ចំណេញ/(ខាត) មុនបង់ពន្ធ (លានរៀល) | ៥៩.១៦៤ | ៤៦.៥៩៥ |
| ចំណេញ/(ខាត) សុទ្ធក្នុងការិយបរិច្ឆេទ (លានរៀល) | ៤៧.២២៦ | ៣៧.៩៦៧ |

| អនុបាតហិរញ្ញវត្ថុ<br>(សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ) | ត្រីមាសទី១ ឆ្នាំ២០២១ | ឆ្នាំ២០២០ |
|---|---|---|
| អនុបាតសាធនភាព | ២២,៥៣% | ២៣,៩៩% |
| អនុបាតបំណុលធៀបនឹងមូលធន | ៤,៥៧ | ៤,៩១ |
| អនុបាតសន្ទនីយភាព | ១៣៨,៤០% | ២៣៥,៣០% |
| អនុបាតឥណទានមិនដំណើរការ | ១,៨៨% | ១,២៧% |
| អនុបាតបញ្ញើឥណទាន | ៦២,៦៨% | ៦២,៦២% |
| | **ត្រីមាសទី១ ឆ្នាំ២០២១** | **ត្រីមាសទី១ ឆ្នាំ២០២០** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | ១,០៩% | ០,៩២% |
| អនុបាតចំណេញធៀបនឹងមូលធន | ៦,២៤% | ៦,៦៣% |
| អនុបាតលទ្ធភាពបង់ការប្រាក់ | ១៩៥,១៣% | ១៦៨,៨៨% |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | N/A | N/A |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | N/A | N/A |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត (ប្រសិនមាន) | N/A | N/A |

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប


















# សមាសភាពក្រុមប្រឹក្សាភិបាល



លោក ប្រ៊ីនលី ដេ ហ្ស៊ីលវ៉ា
ប្រធានក្រុមប្រឹក្សាភិបាល



លោក ខនរ៉ាត ដាយអឺស
អភិបាល



លោក ឌូលីប រ៉ាស៊ីកា សាម៉ារ៉ាវីរ៉ា
អភិបាល



លោក អ៊ីនដ្រាជីត វីជេស៊ីរីវ៉ាដាណា
អភិបាលឯករាជ្យ



លោក ម៉ៃឃើល ម័រម៉ែន
អភិបាលឯករាជ្យ

## សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

សេដ្ឋកិច្ចពិភពលោកត្រូវបានព្យាករណ៍ថានឹងមានកំណើន ៦% នៅក្នុងឆ្នាំ២០២១ និងថយចុះមកត្រឹម ៤,៤% នៅក្នុងឆ្នាំ២០២២។ ការព្យាករណ៍ចុងក្រោយសម្រាប់ឆ្នាំ២០២១ និង២០២២ មានកំណើនខ្លាំងជាងការព្យាករណ៍ដែលធ្វើឡើងនៅក្នុងខែតុលា ឆ្នាំ២០២០ ក្នុងរបាយការណ៍ចក្ខុវិស័យសេដ្ឋកិច្ចពិភពលោក (World Economic Outlook)។ ការព្យាករណ៍ដែលមានកំណើនខ្ពស់ជាងមុននេះឆ្លុះបញ្ចាំងឱ្យឃើញពីការគាំទ្រសារពើពន្ធបន្ថែមពីសេដ្ឋកិច្ចប្រទេសធំៗមួយចំនួន ការងើបឡើងវិញតាមរយៈការចាក់វ៉ាក់សាំងការពារ នៅក្នុងត្រីមាសទី២ ឆ្នាំ២០២១ និងការបន្តសម្របខ្លួនទៅនឹងសកម្មភាពសេដ្ឋកិច្ចដើម្បីភាពប្រសើរឡើង។ ភាពមិនប្រាកដប្រជាមានកម្រិតខ្ពស់ជុំវិញការព្យាករណ៍នេះ ដែលទាក់ទងទៅនឹងការរីករាលដាលនៃជម្ងឺកូវីដ១៩ ប្រសិទ្ធភាពនៃការគាំទ្រគោលនយោបាយដើម្បីជាស្ពានក្នុងការផ្តល់វ៉ាក់សាំងឱ្យបានទូលំទូលាយ និងការវិវត្តនៃស្ថានភាពហិរញ្ញវត្ថុ។

សេដ្ឋកិច្ចប្រទេសកម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនឡើង ៤,០% នៅឆ្នាំនេះ និង ៥,៥% ក្នុងឆ្នាំ២០២២ ដោយសារការងើបឡើងវិញនៃសេដ្ឋកិច្ចប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗ ដែលជួយជម្រុញតម្រូវការសម្រាប់ការនាំចេញរបស់ប្រទេសកម្ពុជា នេះបើយោងតាមរបាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ីចេញផ្សាយនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១។ ផលិតកម្មឧស្សាហកម្មត្រូវបានគេរំពឹងថានឹងកើនឡើង ៧,១% ក្នុងឆ្នាំ២០២១ និង ៧,០% នៅឆ្នាំ២០២២ ដោយសារការងើបឡើងវិញនៃវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងទំនិញសម្រាប់ការធ្វើដំណើរ ក៏ដូចជាកំណើននៃឧស្សាហកម្មធុនស្រាលផ្សេងទៀត ដូចជាផលិតផលអេឡិចត្រូនិច និងកង់។ វិស័យកសិកម្មត្រូវបានរំពឹងថានឹងកើនឡើង ១,៣% ក្នុងឆ្នាំ២០២១ និង ១,២% ក្នុងឆ្នាំ២០២២ ដោយមានការកើនឡើងនៃផលិតផលកសិផលបន្ទាប់ពីរងការខូចខាតដោយទឹកជំនន់កាលពីឆ្នាំមុន ការបន្តមានកំណើននៃវារីវប្បកម្ម និងការហក់ឡើងនៃការនាំចេញផលិតផលកសិកម្ម ទៅកាន់សាធារណរដ្ឋប្រជាមានិតចិន។ វិស័យសេវាកម្មនឹងស្ទុះងើបឡើងវិញក្នុងល្បឿនយឺតៗពោលគឺប្រមាណ ៣,៣% ក្នុងឆ្នាំ២០២១ ទៅ ៦,២% ក្នុងឆ្នាំ២០២២។ វិស័យអចលនទ្រព្យត្រូវបានព្យាករណ៍ថានឹងងើបឡើងវិញពីការធ្លាក់ចុះកាលពីឆ្នាំមុន ដោយមាននិន្នាការស្រដៀងគ្នាទៅនឹងឧស្សាហកម្មសំណង់។

ជាមួយនឹងការវាយប្រហារពីការរាតត្បាតនៃកូវីដ១៩ អិលអូអិលស៊ី (ខេមបូឌា) បានអនុវត្តវិធានការដើម្បីការពារសុវត្ថិភាពបុគ្គលិក និងអតិថិជនរបស់ខ្លួន។ ការសម្របខ្លួនទៅនឹងប្រតិបត្តិការអាជីវកម្ម ព្រមទាំងសកម្មភាពហិរញ្ញវត្ថុត្រូវបានអនុវត្តទាន់ពេលវេលា ស្របពេលនឹងការទទួលយកយ៉ាងឆាប់រហ័សនៃការប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថល។ គិតត្រឹមត្រីមាសទីមួយ ឆ្នាំ២០២១ អិលអូអិលស៊ី (ខេមបូឌា) បានដាក់ឱ្យប្រើប្រាស់បណ្តាញធនាគារឌីជីថលយ៉ាងសម្បូរបែបដែលអនុញ្ញាតឱ្យអតិថិជនធ្វើប្រតិបត្តិការធនាគារដោយខ្លួនឯង គ្រប់ពេលវេលា ដោយពុំចាំបាច់ធ្វើដំណើរទៅធ្វើប្រតិបត្តិការនៅការិយាល័យសាខា។ កម្មវិធី iPay គឺជាកម្មវិធីធនាគារចល័តរបស់ អិលអូអិលស៊ី (ខេមបូឌា) ដែលអនុញ្ញាតឱ្យអតិថិជនរបស់យើងត្រួតពិនិត្យគណនីធនាគាររបស់ពួកគេ និងធ្វើប្រតិបត្តិការយ៉ាងងាយស្រួលតាមរយៈទូរស័ព្ទដៃ។ សេវាធនាគារតាមអ៊ីនធើណែតអនុញ្ញាតឱ្យអតិថិជនធ្វើប្រតិបត្តិការដោយខ្លួនឯង និងគ្រប់ពេលវេលា។ សេវាទូទាត់សងប្រាក់តម្លៃរាយ (RFT). សេវាទូទាត់រហ័ស (FAST) និងប្រព័ន្ធបាគង ជាមួយនឹងធនាគារជាតិនៃកម្ពុជាអនុញ្ញាតឱ្យអតិថិជនអាចផ្ទេរប្រាក់រវាងធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលជាសមាជិកនៃ

គម្រោងទាំងនេះ។ បច្ចុប្បន្ន អិលអូអិលស៊ី (ខេមបូឌា) កំពុងដាក់ឱ្យប្រើប្រាស់សាកល្បងនូវឧបករណ៍ tablets ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងធ្វើឱ្យសេវាកម្មអតិថិជនកាន់តែល្អប្រសើរថែមមួយកម្រិតទៀត។ អិលអូអិលស៊ីក៏បានពង្រីកភាពជាដៃគូរបស់ខ្លួន ដើម្បីពង្រីកបណ្តាលចែកចាយបន្ថែមទៀត និងផ្តល់បទពិសោធន៍ដ៏ល្អប្រសើរដល់អតិថិជនរបស់យើង។

ខ្ញុំបាទសូមឆ្លៀតក្នុងឱកាសនេះ ថ្លែងអំណរគុណដល់សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់សម្រាប់ការដឹកនាំ អរគុណដល់គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់សម្រាប់ការប្តេជ្ញាចិត្ត និងការចូលរួមចំណែកក្នុងការរក្សាបាននូវកំណើនរបស់ក្រុមហ៊ុន ទោះបីជាមានឧបសគ្គប៉ះពាល់ដល់អាជីវកម្ម តាមរយៈការបិទខ្ទប់ និងការរឹតត្បិតការធ្វើដំណើរ។ អ្វីដែលសំខាន់បំផុតគឺការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការរក្សាបាននូវអភិបាលកិច្ចល្អ ហើយសមត្ថភាពក្នុងការធ្វើអាជីវកម្មប្រកបដោយការទទួលខុសត្រូវសង្គម ត្រូវបានទទួលនូវការគោរពពីនិយ័តករ គ្រឹះស្ថានហិរញ្ញវត្ថុ ក៏ដូចជាអតិថិជនផងដែរ។

ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់ធនាគារជាតិនៃកម្ពុជា និងគណៈកម្មការមូលបត្រនៃកម្ពុជា សម្រាប់ការគាំទ្រ និងការផ្តល់អនុសាសន៍។ ខ្ញុំបាទសូមអរគុណយ៉ាងជ្រាលជ្រៅដល់ម្ចាស់ភាគទុនិក អតិថិជន វិនិយោគិន និងដៃគូពាក់ព័ន្ធទាំងអស់សម្រាប់ការគាំទ្រ ការជឿទុកចិត្ត និងភាពជឿជាក់ដែលមានមកលើអិលអូអិលស៊ី ហើយខ្ញុំបាទជឿជាក់ថាអ្នកទាំងអស់គ្នានឹងនៅតែបន្តការគាំទ្រអិលអូអិលស៊ីបន្តទៅមុខជាយូរអង្វែងទៀត។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១

ហត្ថលេខា ត្រា និងឈ្មោះប្រធានក្រុមប្រឹក្សាភិបាល

**លោក ប្រ៊ីនលើ ដេ ហ្ស៊ីលវ៉ា**

**ប្រធានក្រុមប្រឹក្សាភិបាល**

# សេចក្តីថ្លែងរបស់ប្រធាននាយកប្រតិបត្តិ

សេដ្ឋកិច្ចប្រទេសកម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនឡើង ៤,0% នៅឆ្នាំនេះ និង ៥,៥% ក្នុងឆ្នាំ២០២២ ដោយសារការងើបឡើងវិញនៃសេដ្ឋកិច្ចប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗ ដែលជួយជម្រុញតម្រូវការសម្រាប់ការនាំចេញរបស់ប្រទេសកម្ពុជា។ ថ្វីត្បិតតែកម្ពុជាកំពុងប្រឈមនឹងការរាតត្បាតនៃជម្ងឺកូវីដ១៩ ជាពិសេសការឆ្លងរាលដាលនៅក្នុងសហគមន៍ដែលចាប់ផ្តើមនៅក្នុងខែកុម្ភៈ ឆ្នាំ២០២១ ប៉ុន្តែរាជរដ្ឋាភិបាលបានឆ្លើយតបយ៉ាងរហ័សចំពោះករណីថ្មីៗដែលកើតឡើង ហើយយើងរំពឹងថាសេដ្ឋកិច្ចនឹងវិលត្រឡប់មករកកំណើនវិញក្នុងឆ្នាំ២០២១ នេះបើយោងតាមរបាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ីចេញផ្សាយនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១។ កំណើននេះនឹងជួយបង្កើនប្រាក់ចំណូលគ្រួសារ ប៉ុន្តែមិនមែនគ្រប់វិស័យ និងតំបន់ទាំងអស់នឹងទទួលបានប្រយោជន៍នេះស្មើគ្នានោះទេ ដូច្នេះវាចាំបាច់ណាស់ ក្នុងការតាមដានមើលជីវភាពគ្រួសារទាំងឡាយ ក៏ដូចជាតម្រូវការគាំទ្របន្ថែមឱ្យបានជិតដល់។

ឆ្លើយតបទៅនឹងផលប៉ះពាល់ដែលបណ្តាលមកពីការរីករាលដាលនៃកូវីដ១៩ អិលអូអិលស៊ីបានបន្តផ្តល់ការអនុគ្រោះដល់អតិថិជនរបស់ខ្លួនដែលប្រាក់ចំណូលរងផលប៉ះពាល់ធ្ងន់ធ្ងរពីការរីករាលដាលនៃកូវីដ១៩ ជាពិសេសលើវិស័យទេសចរណ៍ សំណង់ វិស័យកាត់ដេរ និងវិស័យផ្សេងៗទៀត។ ទោះបីជាបរិយាកាសប្រតិបត្តិការមានបញ្ហាប្រឈមខ្លាំងសម្រាប់សេដ្ឋកិច្ចពិភពលោក អិលអូអិលស៊ីនៅតែអាចរក្សាបាននូវគុណភាពឥណទានល្អ ត្រឹមត្រីមាសទី១ ឆ្នាំ២០២១ ដោយសារតែអិលអូអិលស៊ីបានធ្វើប្រតិបត្តិការប្រកបដោយភាពប្រុងប្រយ័ត្ន។ ទ្រព្យសកម្មរបស់អិលអូអិលស៊ីកើនឡើងដល់ជាង ៤.៣៤០ ពាន់លានរៀល។ សមតុល្យប្រាក់បញ្ញើកើនឡើងដល់ ២.២៧២ ពាន់លានរៀល ដែលមានកំណើន ៥% ធៀបនឹងសមតុល្យនៅដំណាច់ឆ្នាំ២០២០។ ផលប័ត្រឥណទានកើនឡើងដល់ ៣.៦២៥ ពាន់លានរៀល ដែលមានកំណើន ៥% ធៀបនឹងដំណាច់ឆ្នាំ២០២០ ខណៈដែលហានិភ័យផលប័ត្រឥណទានធំជាង៣០ថ្ងៃ មានចំនួន ១,៨៨%។

ដើម្បីចូលរួមចំណែកក្នុងការបង្ការ និងគ្រប់គ្រងការរីករាលដាលនៃកូវីដ១៩ តាមរយៈការប្រើប្រាស់ក្រដាសប្រាក់ អិលអូអិលស៊ីបានលើកទឹកចិត្តអតិថិជនរបស់ខ្លួនឱ្យប្រើប្រាស់ផលិតផលឌីជីថលដែលមានស្រាប់ និងការទូទាត់តាមមធ្យោបាយអេឡិចត្រូនិចយ៉ាងសម្បូរបែប ដូចជា តាមរយៈកម្មវិធី iPay Cambodia ដែលជាកម្មវិធីធនាគារចល័តតាមទូរស័ព្ទដៃ តាមប្រព័ន្ធបាគង ប្រព័ន្ធទូទាត់រហ័ស (FAST) ប្រព័ន្ធទូទាត់តម្លៃរាយ (RFT) និងសេវាធនាគារតាមអ៊ីនធើណែត។ ដូច្នេះ ទោះជាមានការរឹតត្បិតការធ្វើដំណើរ អតិថិជនរបស់អិលអូអិលស៊ីនៅតែអាចធ្វើប្រតិបត្តិការធនាគារបានយ៉ាងងាយស្រួលពីទូរស័ព្ទរបស់ពួកគេ។ បន្ថែមលើនេះ អតិថិជនអិលអូអិលស៊ីអាចដកសាច់ប្រាក់នៅតាមម៉ាស៊ីនអេធីអឹមជាច្រើនកន្លែងរបស់គ្រឹះស្ថានដែលជាសមាជិកប្រព័ន្ធ CSS។

ក្នុងឆ្នាំ២០២១ អិលអូអិលស៊ីនឹងបន្តលើកកម្ពស់សេវាឌីជីថលដែលមានស្រាប់ អភិវឌ្ឍផលិតផលថ្មីៗដើម្បីបញ្ចូលទៅក្នុងបណ្តាញឌីជីថលដែលមានស្រាប់ ដែលនឹងជួយពង្រឹងសេវាអតិថិជនឱ្យកាន់តែប្រសើរឡើង និងបង្កើនប្រសិទ្ធភាពការងារ។ ក្រៅពីនេះ អិលអូអិលស៊ីបាននឹងកំពុងដាក់ឱ្យប្រើប្រាស់សាកល្បងនូវប្រព័ន្ធធនាគារតាមឧបករណ៍ tablet ដែលអនុញ្ញាតឱ្យបុគ្គលិករបស់យើងធ្វើប្រតិបត្តិការ (ការវាយតម្លៃឥណទាន ការប្រមូលឥណទាន និងការបើកគណនីបញ្ញើសំចៃ) ពីឧបករណ៍ Tablet Devices ដែលនឹងជួយបង្កើនផលិតភាព និងប្រសិទ្ធភាពការងារឱ្យកាន់តែល្អប្រសើរ។ បន្ថែមលើនេះ អិលអូអិលស៊ីក៏បាននឹងកំពុងធ្វើសមាហរណកម្មជាមួយភាគីទីបី ដើម្បីផ្តល់នូវបណ្តាញចែកចាយកាន់តែច្រើន និងផ្តល់បទពិសោធន៍ដ៏ល្អប្រសើរដល់អតិថិជនរបស់យើង។

សរុបជារួមមក  អិលអូអិលស៊ីនឹងខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាពក្នុងការចាប់យកឱកាសជោគជ័យ  ហើយយើងជឿជាក់ថា អិលអូអិលស៊ីនឹងអាចនាំមកនូវតម្លៃបន្ថែមទៀតដល់អតិថិជន វិនិយោគិន និងម្ចាស់ភាគទុនិក។

ជាចុងក្រោយ   ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាលសម្រាប់ការដឹកនាំ   អរគុណដល់គណៈគ្រប់គ្រង បុគ្គលិក អតិថិជន វិនិយោគិន និងដៃគូពាក់ព័ន្ធទាំងអស់ ដែលតែងតែគាំទ្រអិលអូអិលស៊ីដើម្បីភាពរីកចម្រើនទាំងអស់គ្នា។   ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់ធនាគារជាតិនៃកម្ពុជា   និងគណៈកម្មការមូលបត្រនៃកម្ពុជាសម្រាប់ការផ្តល់នូវវិធានការគាំទ្រ និងការផ្តល់អនុសាសន៍ ដើម្បីធានាឱ្យបាននូវនិរន្តរភាពនៃគ្រឹះស្ថានហិរញ្ញវត្ថុ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១

ហត្ថលេខា ត្រា និងឈ្មោះប្រធាននាយកប្រតិបត្តិ

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី
LOLC (CAMBODIA) Plc.
KINGDOM OF CAMBODIA

លោក សុខ ជឿន

ប្រធាននាយកប្រតិបត្តិ

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប....................i
ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប....................ii
សមាសភាពក្រុមប្រឹក្សាភិបាល....................iii
សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល....................iv
សេចក្តីថ្លែងរបស់ប្រធាននាយកប្រតិបត្តិ....................vi
ផ្នែកទី ១៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ....................1
ក-អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ....................1
ខ-លក្ខណៈនៃធុរកិច្ច....................1
គ-ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ....................1
ផ្នែកទី ២៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច....................2
ក-លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក....................2
ខ-រចនាសម្ព័ន្ធចំណូល....................2
ផ្នែកទី ៣៖ របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ....................3
ផ្នែកទី ៤៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង....................4
ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ....................4
ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ....................6
គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល....................6
ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ....................6
ង-ផលប៉ះពាល់នៃអតិផរណា....................6
ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល....................6
ផ្នែកទី ៥៖ ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន (ប្រសិនមាន)....................7
ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ....................8

## ផ្នែកទី ១៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

### ក-អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

- ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ៖ **អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី** ជាអក្សរឡាតាំង៖ LOLC (Cambodia) Plc.
- លេខកូដស្តង់ដារ៖ KH២០០០០៨១៩៥៣ (FX-Indexed Bond) និង KH២០០០០៨២៩៥១ (Plain Bond)
- ទីស្នាក់ការ៖ **អគារលេខ ៦៦B ផ្លូវលេខ ២៧១ សង្កាត់បឹងទំពុនទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ**
- លេខទូរស័ព្ទ៖ (៨៥៥) ២៣ ៩៩១ ៩៩១ លេខទូរសារ៖ (៨៥៥) ២៣ ២២០ ៦៤២
- គេហទំព័រ៖ www.lolc.com.kh អ៊ីម៉ែល៖ info@lolc.com.kh
- លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម៖ ០០០១២៨២៩ កាលបរិច្ឆេទ៖ **ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥**
- លេខអាជ្ញាបណ្ណអាជីវកម្ម៖ M.F 04 ចេញដោយ៖ **ធនាគារជាតិនៃកម្ពុជា** កាលបរិច្ឆេទ៖ **ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨**
- សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន លេខ៖ ០៨៤/១៩ គ.ម.ក/ស.ស.រ.
  កាលបរិច្ឆេទ៖ **ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩**
- ឈ្មោះបុគ្គលតំណាងបុគ្គលបោះផ្សាយ៖ **លោក សុខ ជឿន**

### ខ-លក្ខណៈនៃធុរកិច្ច

អិលអូអិលស៊ី គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើធំមួយនៅក្នុងប្រទេសកម្ពុជា ដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា និងបានធ្វើប្រតិបត្តិការជាង ២៦ឆ្នាំមកហើយ។ អិលអូអិលស៊ីផ្តល់សេវាហិរញ្ញវត្ថុយ៉ាងសម្បូរបែបដល់អតិថិជនរបស់ខ្លួនរួមមាន សេវាឥណទាន សេវាប្រាក់បញ្ញើសំចៃ ភតិសន្យាហិរញ្ញវត្ថុ សេវាផ្ទេរប្រាក់ សេវាធនាគារចល័ត និងសេវាទូទាត់វិក្កយបត្រ។ ជាមួយនឹងបដិវត្តនៃបច្ចេកវិទ្យា អិលអូអិលស៊ីបាននឹងកំពុងផ្តល់សេវាហិរញ្ញវត្ថុឌីជីថល ដើម្បីពង្រីកបណ្តាញចែកចាយបន្ថែមទៀត និងផ្តល់នូវសេវាអតិថិជនដ៏ល្អប្រសើរជូនអតិថិជនដូចជា កម្មវិធីធនាគារចល័ត iPay Mobile Application សេវាធនគារតាមអ៊ីនធើណែត បាគង សេវាទូទាត់រហ័ស (FAST). CSS និងសេវាទូទាត់សងប្រាក់តម្លៃរាយ (RFT)។ គិតត្រឹមខែមីនា ឆ្នាំ២០២១ សមតុល្យប្រាក់បញ្ញើរបស់អិលអូអិលស៊ីមានចំនួនជាង ២.២៧២ ពាន់លានរៀល ជាមួយនឹងចំនួនអតិថិជនជាង ៤២៤ ពាន់នាក់។ ផលប័ត្រឥណទានសរុបកើនឡើងដល់ ៣.៦២៦ ពាន់លានរៀល និងមានអតិថិជនជាង ៣០៥ ពាន់នាក់។

### គ-ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

គិតត្រឹមត្រីមាសទីមួយ ឆ្នាំ២០២១ អិលអូអិលស៊ី (ខេមបូឌា) បានដាក់ឱ្យប្រើប្រាស់បណ្តាញធនាគារឌីជីថលយ៉ាងសម្បូរបែប ដែលអនុញ្ញាតឱ្យអតិថិជនធ្វើប្រតិបត្តិការធនាគារដោយខ្លួនឯង គ្រប់ពេលវេលា ដោយពុំចាំបាច់ធ្វើដំណើរទៅធ្វើប្រតិបត្តិការនៅការិយាល័យសាខា។ កម្មវិធី iPay គឺជាកម្មវិធីធនាគារចល័តរបស់ អិលអូអិលស៊ី (ខេមបូឌា) ដែលអនុញ្ញាតឱ្យអតិថិជនរបស់យើងត្រួតពិនិត្យគណនីធនាគាររបស់ពួកគេ និងធ្វើប្រតិបត្តិការយ៉ាងងាយស្រួលតាមរយៈទូរស័ព្ទដៃ។ សេវាធនាគារតាមអ៊ីនធើណែតអនុញ្ញាតឱ្យអតិថិជនធ្វើប្រតិបត្តិការដោយខ្លួនឯង និងគ្រប់ពេលវេលា។ សេវាទូទាត់សងប្រាក់តម្លៃរាយ (RFT). សេវាទូទាត់រហ័ស (FAST) និងប្រព័ន្ធបាគង ជាមួយនឹងធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យអតិថិជនអាចផ្ទេរប្រាក់រវាងធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលជាសមាជិកនៃគម្រោងទាំងនេះ។ បច្ចុប្បន្ន អិលអូអិលស៊ី (ខេមបូឌា) កំពុងដាក់ឱ្យប្រើប្រាស់សាកល្បងនូវឧបករណ៍ tablets ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងធ្វើឱ្យសេវាកម្មអតិថិជនកាន់តែល្អប្រសើរថែមមួយកម្រិតទៀត។ អិលអូអិលស៊ីក៏បានពង្រីកភាពជាដៃគូរបស់ខ្លួន ដើម្បីពង្រីកបណ្តាលចែកចាយបន្ថែមទៀត និងផ្តល់បទពិសោធន៍ដ៏ល្អប្រសើរដល់អតិថិជនរបស់យើង។

# ផ្នែកទី ២៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក-លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

| លទ្ធផលសម្រេចបានសំខាន់ៗ | ផែនការ | លទ្ធផលសម្រេចបាន |
|---|---|---|
| **ផ្នែកសេវាឥណទាន** | | |
| ចំនួនអតិថិជនសេវាឥណទាន | ៣១៤.៩៥២ | ៣០៥.៤៨៩ |
| ឥណទាននៅក្នុងដៃអតិថិជន (លានរៀល) | ៣.៨៦១.០២៦ | ៣.៦២៥.៩៥៦ |
| **ផ្នែកសេវាប្រាក់បញ្ញើសន្សំ** | | |
| ចំនួនអតិថិជនប្រាក់បញ្ញើសន្សំ | ៤៩៨.៤១៧ | ៤២៣.៦៣៣ |
| សមតុល្យប្រាក់បញ្ញើសន្សំ (លានរៀល) | ២.៤៥៤.៤៨៥ | ២.២៧២.៨៣១ |
| **ផ្នែកប្រតិបត្តិការសំខាន់ផ្សេងៗទៀត** | | |
| ចំនួនការិយាល័យ | ៨១ | ៧៩ |
| ចំនួនបុគ្គលិក | ៣.៣០៥ | ៣.២៨៥ |

## ខ-រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី១ ឆ្នាំ២០២១ | | ត្រីមាសទី១ ឆ្នាំ២០២០ | |
|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ |
| ១ | ចំណូលការប្រាក់ | ១៧១.៦៥៥ | ៩៥,៥៣% | ១៦៨.៦១៤ | ៩៦,១៩% |
| ២ | ចំណូលផ្សេងៗ | ៨.០២៥ | ៤,៤៧% | ៦.៦៧៣ | ៣,៨១% |
| ចំណូលសរុប | | **១៧៩.៦៨០** | **១០០%** | **១៧៥.២៨៧** | **១០០%** |

## ផ្នែកទី ៣៖ របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមពិនិត្យមើលរបាយការណ៍លម្អិតនៅក្នុងឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ។

## ផ្នែកទី ៤៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះ គឺជាការពិភាក្សាលើលទ្ធផលនៃប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុដោយគណៈគ្រប់គ្រងរបស់អិលអូអិលស៊ី ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុរបស់អិលអូអិលស៊ី ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ គណៈគ្រប់គ្រងធ្វើការពិភាក្សា និងវិភាគលើសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗ ដែលបានជះឥទ្ធិពលទៅ លើប្រាក់ចំណេញរបស់អិលអូអិលស៊ីតែប៉ុណ្ណោះ។

### ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

#### ១-ការវិភាគចំណូល

អិលអូអិលស៊ីមានចំណូល ២ ប្រភេទធំៗ គឺចំណូលពីការប្រាក់ និងចំណូលផ្សេងៗ។

- **ចំណូលពីការប្រាក់រួមមាន៖** កម្រៃជើងសារពីឥណទាន ចំណូលការប្រាក់សុទ្ធដែលទទួលបានពីការផ្តល់ឥណទានដល់អតិថិជន និងពីការដាក់ប្រាក់បញ្ញើនៅតាមបណ្តាធនាគារនានា ដែលចំណូលទាំងនេះត្រូវទទួលស្គាល់ជាប្រចាំខែ។
- **ចំណូលផ្សេងៗរួមមាន៖** ចំណូលបានពីការផាកពិន័យ ចំណូលបានពីការប្រមូលឥណទានលុបចោល ចំណេញពីការប្តូរប្រាក់ កម្រៃផ្សេងៗ ។ល។

#### ២-ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល | ត្រីមាសទី១ ឆ្នាំ២០២១ | | ត្រីមាសទី១ ឆ្នាំ២០២០ | |
|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ |
| ១ | ចំណូលការប្រាក់ | ១៧១.៦៥៥ | ៩៥,៥៣% | ១៦៨.៦១៤ | ៩៦,១៩% |
| ២ | ចំណូលផ្សេងៗ | ៨.០២៥ | ៤,៤៧% | ៦.៦៧៣ | ៣,៨១% |
| **ចំណូលសរុប** | | **១៧៩.៦៨០** | **១០០%** | **១៧៥.២៨៧** | **១០០%** |

ចំណូលពីការប្រាក់ជាចំណូលដ៏ធំ និងសំខាន់សម្រាប់អិលអូអិលស៊ី ដែលមានរហូតដល់ ៩៥,៥៣% នៃចំណូលសរុប។

#### ៣-ការវិភាគគម្លាតចំណេញដុល

អិលអូអិលស៊ី បានរៀបចំរបាយការណ៍លទ្ធផលរបស់ខ្លួន ក្នុងទម្រង់ជារបាយការណ៍ដែលពុំមានការបង្ហាញឱ្យឃើញនូវគំលាតចំណេញដុលនោះទេ។ ប៉ុន្តែទម្រង់របាយការណ៍នេះអាចឱ្យយើងធ្វើការពិភាក្សា និងវិភាគលើចំណេញពីប្រតិបត្តិការដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិការ។ ចំណាយប្រតិបត្តិការនឹងលើកយកមកពិភាក្សា និងវិភាគនៅចំណុច ៤. ការវិភាគចំណេញ/ខាតមុនបង់ពន្ធ។

### ៤-ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| តារាងសង្ខេបប្រាក់ចំណេញ (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២០ | ត្រីមាសទី១ ឆ្នាំ២០២១ | បម្រែបម្រួល (លានរៀល) | បម្រែបម្រួល % |
|---|---|---|---|---|
| ចំណូលការប្រាក់ | ១៦៧.៥៧៣ | ១៧១.៦៥៥ | ៤.០៨២ | ២,៤៤% |
| ចំណាយការប្រាក់ | (៦២.៩៦៦) | (៦២.១៩៣) | ៧៧៣ | -១,២៣% |
| **ចំណូលពីការប្រាក់សុទ្ធ** | **១០៤.៦០៧** | **១០៩.៤៦២** | **៤.៨៥៥** | **៤,៦៤%** |
| ចំណូលផ្សេងៗ | ៦.០៤៥ | ៨.០២៥ | ១.៩៨០ | ៣២,៧៥% |
| ចំណាយលើបុគ្គលិក | (២៩.២៤០) | (៣៤.១១៤) | (៤.៨៧៤) | ១៦,៦៧% |
| រំលស់លើទ្រព្យរូបី និងទ្រព្យអរូបី | (២.៤៣៥) | (២.៦៤២) | (២០៧) | ៨,៥០% |
| ចំណាយរដ្ឋបាល និងចំណាយផ្សេងៗ | (៩.៩៣៤) | (១១.៤៩៣) | (១.៥៥៩) | ១៥,៦៩% |
| **ចំណេញពីប្រតិបត្តិការ** | **៦៩.០៤៣** | **៦៩.២៣៨** | **១៩៥** | **០,២៨%** |
| សំវិធានធនលើឧបករណ៍ហិរញ្ញវត្ថុ | ៣.៨០៩ | (១០.០៧៤) | (១៣.៨៨៣) | -៣៦៤,៤៨% |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **៧២.៨៥២** | **៥៩.១៦៤** | **(១៣.៦៨៨)** | **-១៨,៧៩%** |

ក្នុងត្រីមាសទី១ ឆ្នាំ២០២១ អិលអូអិលស៊ីសម្រេចបានប្រាក់ចំណេញមុនបង់ពន្ធចំនួន ៥៩.១៦៤ លានរៀល ដែលត្រីមាសទី៤ ឆ្នាំ២០២០ មានចំនួន ៧២.៨៥២ លានរៀល ដែលថយចុះ ១៣.៦៨៨ លានរៀល ស្មើនឹង ១៨,៧៩%។ មូលហេតុចម្បងនៃការថយចុះនេះគឺដោយសារតែការកើនឡើងសំវិធានធនលើឧបករណ៍ហិរញ្ញវត្ថុ ចំនួន ១៣.៨៨៣ លានរៀល ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០២០។

### ៥-ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| តារាងសង្ខេបប្រាក់ចំណេញ (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២០ | ត្រីមាសទី១ ឆ្នាំ២០២១ | បម្រែបម្រួល (លានរៀល) | បម្រែបម្រួល % |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ៧២.៨៥២ | ៥៩.១៦៤ | (១៣.៦៨៨) | -១៨,៧៩% |
| ចំណាយពន្ធលើប្រាក់ចំណេញ | (៤.៥៨២) | (១១.៩៣៨) | (៧.៣៥៦) | ១៦០,៥៤% |
| ប្រាក់ចំណេញក្រោយបង់ពន្ធ | ៦៨.២៧០ | ៤៧.២២៦ | (២១.០៤៤) | -៣០,៨២% |

ក្នុងត្រីមាសទី១ ឆ្នាំ២០២១ អិលអូអិលស៊ីសម្រេចបានប្រាក់ចំណេញសុទ្ធចំនួន ៤៧.២២៦ លានរៀល ដែលថយចុះ ៣០,៨២%។ មូលហេតុចម្បងនៃការថយចុះនេះគឺដោយសារតែការថយចុះនៃប្រាក់ចំណេញមុនបង់ពន្ធ ចំនួន ១៣.៦៨៨ លានរៀល។

### ៦-ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

នាដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ គណៈគ្រប់គ្រងយល់ថា អិលអូអិលស៊ីពុំមានកត្តា និងនិន្នាការដែលប៉ះពាល់ដល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុរបស់អិលអូអិលស៊ីដែលគួរអោយកត់សម្គាល់ឡើយ។

**ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ**

**១-ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់**

អិលអូអិលស៊ី ជាស្ថាប័នហិរញ្ញវត្ថុដ៏ធំមួយក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ដែលតែងយកចិត្តទុកដាក់ទៅលើគុណភាពនៃការផ្តល់សេវាកម្ម ដើម្បីបង្កភាពងាយស្រួលសម្រាប់អតិថិជនទូទៅក្នុងការប្រើប្រាស់ផលិតផល និងសេវារបស់អិលអូអិលស៊ី។ តាមបទពិសោធន៍នាពេលកន្លងមកនេះ អិលអូអិលស៊ី ទទួលបាននូវការគាំទ្រយ៉ាងខ្លាំងពីសំណាក់អតិថិជនប្រាក់កម្ចី អតិថិជនភតិសន្យាហិរញ្ញវត្ថុ និងអតិថិជនប្រាក់បញ្ញើ ដែលធ្វើឱ្យយើងមានការរីកចម្រើនយ៉ាងខ្លាំង និងឆាប់រហ័ស ក្នុងរយៈពេលដ៏ខ្លីចុងក្រោយនេះ។

**២-ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម**

នាដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ គណៈគ្រប់គ្រងយល់ថា អិលអូអិលស៊ី ពុំមានធាតុដែលខុសពីធម្មតាទេ។

**៣-ការវិភាគលើពន្ធ**

អិលអូអិលស៊ី ស្ថិតក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារដូចនេះ អិលអូអិលស៊ី មានភារកិច្ចបង់ពន្ធទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន។ អិលអូអិលស៊ីមានភារកិច្ចបង់ពន្ធអាករទៅតាមរបបពិត និងសហគ្រាសជាប់ពន្ធធំ ដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។

**៤-ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ**

នាដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ គណៈគ្រប់គ្រងយល់ថា អិលអូអិលស៊ី ពុំមានធាតុដែលខុសពីធម្មតា និងវិសាមញ្ញនោះទេ។

**គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល**

នាដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ គណៈគ្រប់គ្រងយល់ថា អិលអូអិលស៊ីពុំមានធាតុដែល ជាការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូលខុសពីធម្មតាទេ។

**ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ**

អិលអូអិលស៊ី បានកត់ត្រាបញ្ជីគណនេយ្យដោយប្រើប្រាស់រូបិយប័ណ្ណគោលគឺ ប្រាក់រៀល។ ប្រតិបត្តិការជារូបិយប័ណ្ណប្រាក់ដុល្លារ និងថៃបាត ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ។ សមតុល្យនៃទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុនាកាលបរិច្ឆេទរាយការណ៍ ដែលជារូបិយប័ណ្ណក្រៅពីប្រាក់រៀលក៏ត្រូវបានប្តូរទៅជាប្រាក់រៀលដោយប្រើអត្រានាកាលបរិច្ឆេទនោះ។ ភាពលម្អៀងពីការប្តូររូបិយប័ណ្ណដែលកើតមកពីការប្តូរនោះត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល។

**ង-ផលប៉ះពាល់នៃអតិផរណា**

អិលអូអិលស៊ី មិនបានកែប្រែអត្រាការប្រាក់ ដោយផ្អែកតាមការប្រែប្រួលនៃអតិផរណាទេ ពោលគឺផ្អែកទៅលើស្ថានភាពប្រកួតប្រជែងជាក់ស្តែងនៅក្នុងទីផ្សារ ហើយនៅតែរក្សាបាននូវចីរភាពហិរញ្ញវត្ថុយ៉ាងល្អប្រសើរ។

**ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល**

នាដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ នេះ គណៈគ្រប់គ្រងយល់ថា អិលអូអិលស៊ី ពុំបានទទួលរងការប៉ះពាល់ពីគោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រដ្ឋាភិបាលជាសារវន្តនោះទេ។

## ផ្នែកទី ៥៖ ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន (ប្រសិនមាន)

នៅក្នុងត្រីមាសនេះ ពុំមានព័ត៌មានចាំបាច់ផ្សេងទៀតដែលត្រូវរាយការណ៍ទេ។

## ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

(ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលយ៉ាងតិច ២រូប)

កាលបរិច្ឆេទ៖ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១
បានអាន និងឯកភាព

______________________

លោក ប្រ៊ីនលី ដេ ហ្ស៊ីលវ៉ា
ប្រធានក្រុមប្រឹក្សាភិបាល

**គំនិតរីកចម្រើន Ideas for Growth**

អគារលេខ ៦៦៦បេ ផ្លូវលេខ២៧១ ភូមិក្បាលទំនប់១ សង្កាត់បឹងទំពុនទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទលេខ៖ (+៨៥៥) ២៣ ៩៩១ ៩៩១ | អ៊ីម៉ែល៖ info@lolc.com.kh | **Facebook: facebook.com/lolccambodia**

គេហទំព័រ៖ **www.lolc.com.kh**

ឯកសារសាធារណៈ